# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៤ សសរ

# សេចក្ដីសំរេច

## ស្ដីពី

## ការបង្កើតក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ

-------

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០៩៩៦/ ១៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងទេសចរណ៍
- តាមការចាំបាច់ចំពោះមុខរបស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១:** ត្រូវបានបង្កើតក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ ដែលមានសមាសភាព ដូចតទៅ :

| | | | |
|---|---|---|---|
| ១- | ឯកឧត្ដម **វេង សេរីវុឌ្ឍ** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | ប្រធាន |
| ២- | ឯកឧត្ដម **ថោង ខុន** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធានប្រចាំការ |
| ៣- | ឯកឧត្ដម **ទី ចន្ទផល** | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | អនុប្រធាន |
| ៤- | ឯកឧត្ដម **ជុក គឿន** | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៥- | ឯកឧត្ដម **ឡុង វិសាលោ** | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

| | | | | |
|---|---|---|---|---|
| ៦- | ឯកឧត្តម | **ញាណ ឡេង** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧- | ឯកឧត្តម | **ធីក គ្រឿនធុគ្គា** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៨- | ឯកឧត្តម | **វ៉ែត សារិន** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៩- | ឯកឧត្តម | **មាស គីមសុថារ៉ូ** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ | សមាជិក |
| ១០- | ឯកឧត្តម | **ទេព សាខុន** | អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១១- | ឯកឧត្តម | **ហ៊ុល លឹម** | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១២- | ឯកឧត្តម | **សៅ សុខុន** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១៣- | ឯកឧត្តម | **គីម ស៊ីថន** | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៤- | ឯកឧត្តម | **ថាច់ ផែន** | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ១៥- | ឯកឧត្តម | **ស៊ឹម សួង** | តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៦- | ឯកឧត្តម | **អ៊ុក សារមេត្ត** | អគ្គនាយករងអាជ្ញាធរអប្សរា | សមាជិក |
| ១៧- | លោក | **ជ ឡេងហួង** | អគ្គនាយករង នៃធនាគារអភិវឌ្ឍន៍ជនបទ | សមាជិក |

**ប្រការ ២:** ក្រុមការងារទេសចរណ៍ សំរាប់កាត់បន្ថយភាពក្រីក្រ មានមុខងារ និងភារកិច្ចដូចតទៅ :

- អនុវត្ត និងសំរបសំរួលតាមគោលនយោបាយ និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដើម្បីសិក្សាអំពីទំនាក់ទំនងរវាង ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព ដោយរៀបចំ កសាង គំរោងបង្ហាញការកាត់បន្ថយភាពក្រីក្រ
- បង្កើតបញ្ជីរួម និងបញ្ជីអាទិភាពនៃតំបន់អភិវឌ្ឍន៍វិស័យទេសចរណ៍ សំរាប់កាត់បន្ថយភាពក្រីក្រដែលផ្ដោតទៅលើតំបន់ទីក្រុង និងជនបទ
- កសាងភូមិទេសចរណ៍មូលដ្ឋានមួយចំនួន សំរាប់ធ្វើការដកពិសោធន៍ និងធ្វើជាគំរូតាមរូបមន្តនៃចលនា "ភូមិមួយផលិតផលមួយ" ព្រមទាំងបង្កើត ពង្រឹង និងពង្រីកសហគ្រាសខ្នាតតូច និងមធ្យម
- ជំរុញ ដឹកនាំ និងគ្រប់គ្រងរាល់ការងារផ្សព្វផ្សាយព័ត៌មាន អំពីទីផ្សារទេសចរណ៍ទាំងក្នុង និងក្រៅប្រទេសលើវិស័យទេសចរណ៍ក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្រ
- សហការជាមួយអាជ្ញាធរអប្សរាក្នុងការលើកផែនការរួម និងដោយឡែក រាល់ការអភិវឌ្ឍវិស័យទេសចរណ៍ ក្នុងតំបន់សៀមរាបអង្គរ និងតំបន់ដែលមានការពាក់ព័ន្ធ
- ស្វែងរក និងទទួលជំនួយឧបត្ថម្ភផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដើម្បីបំរើការងារខាងលើ

- ធ្វើរបាយការណ៍ ស្តីពីសកម្មភាពរបស់ក្រុមការងារ ដោយលើកសំណូមពរ និងវិធានការនានាជូនប្រមុខរាជរដ្ឋាភិបាល ពិនិត្យសំរេចតាមដំណាក់កាលនីមួយៗ ។

**ប្រការ ៣:** - ក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងទេសចរណ៍ ក្នុងការបំពេញការងារ ។

- សមាជិកនៃក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ ។

**ប្រការ ៤:** ក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រមានលេខាធិការដ្ឋានមួយជាជំនួយការ ដែលមានទីតាំងនៅទីស្តីការក្រសួងទេសចរណ៍ ។

**ប្រការ ៥:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័ន ប្រធានអគ្គនាយកអាជ្ញាធរអប្សរា និងអភិបាលខេត្ត-ក្រុងពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ